# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ ពន្យល់អត្ថន័យនៃពាក្យខ្មែរថា ថ្វាយបង្គំព្រះពុទ្ធប្រយ័ត្នប៉ះស៊ីម៉ង់ត៍ ថ្វាយបង្គំព្រះសង្ឃប្រយ័ត្នប៉ះកូនអ្នកស្រុក ថ្វាយបង្គំព្រះធម៌ប្រយ័ត្នប៉ះសាស្ត្រាស្លឹករឹត ។

www.hoksavann,com

ថ្ងៃទី៣ មករា ២០១១



ពាក្យខ្មែរថា ថ្វាយបង្គំព្រះពុទ្ធប្រយ័ត្នប៉ះស៊ីម៉ង់ត៍ ថ្វាយបង្គំព្រះសង្ឃប្រយ័ត្នប៉ះកូនអ្នកស្រុក ថ្វាយបង្គំព្រះធម៌ប្រយ័ត្នប៉ះសាស្ត្រាស្លឹករឹតនេះ ជាពាក្យរំលឹកពុទ្ធសាសនិកជនខ្មែរ កុំឲ្យប្រើចិត្តខុសក្នុងការថ្វាយបង្គំចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ តែថ្វាយបង្គំគោរពដល់គុណធម៌ របស់ព្រះរតនៈទាំងបីនេះវិញទេ ។

តាមការស្រាវជ្រាវ កាលសម័យដើម ពុំទាន់មានគូរព្រះរូបព្រះពុទ្ធគោរពឡើយ បើចង់សំគាល់ថា ព្រះអង្គសំដែងធម្មចក្រ គេគូរជារូបវង់មូលប្រកបដោយកាំ៨ ជានិមិត្តរូបនៃការសំដែង ធម្មចក្រ ។ គេគូររូបដើមពោធិព្រឹក្សជានិមិត្តរូបកន្លែងត្រាស់ដឹង ។ កន្លែងប្រសូត គេគូររូបដើមរាំងជាដើម ។ លុះសម័យក្រោយមក ទើបមានគូររូបព្រះពុទ្ធនិងរូបផ្សេងៗទៀតស្របតាមរឿងរ៉ាវ ដែលមាននិយាយក្នុងពុទ្ធប្រវត្តិ ។ សម្ភារៈដែលគេយកទៅធ្វើជាព្រះពុទ្ធរូបពុំមែនយកពីស៊ីម៉ង់ត៍ទៅធ្វើទេ គឺគេធ្វើពីថ្ម ពីមាស ពីប្រាក់ ពីឈើ ពីក្រដាស ។ ព្រះពុទ្ធបានរំលត់ខន្ធបរិនិព្វានបាត់ទៅហើយ ការកសាងព្រះរូបព្រះពុទ្ធគោរពនេះ ហាក់ដូចជាព្រះពុទ្ធជាម្ចាស់គង់នៅចំពោះមុខពុទ្ធបរិស័ទ ដែលថ្វាយបង្គំនឹកដល់គុណរបស់ព្រះអង្គ គឺបញ្ញាគុណ វិសុទ្ធិគុណ និង ករុណាគុណ ។ ព្រះរូបនេះជានិមិត្តរូបអ្នកស្នងព្រះអង្គ ហើយដើម្បីឲ្យពេញលក្ខណៈ ពុទ្ធបរិស័ទបាននិមន្តព្រះសង្ឃធ្វើពិធី អភិសេក សន្មត់ជាព្រះពុទ្ធរូប គួរគោរព គួរបូជា ពុំមែននៅជាសម្ភារៈមានស៊ីម៉ង់ត៍ជាដើមឡើយ ។ ការអភិសេកនេះទៀត ក៏ពុំមែនបានន័យថា ឲ្យព្រះវិញ្ញាណរបស់ព្រះអង្គមកសណ្ឋិតនៅក្នុងព្រះរូបនោះឡើយ ។ ក្នុងបាលីវេរចង្ក្រាន់មួយឃ្លាថា ពុទ្ធប្បមុខស្ស ប្រែជាសេចក្ដីថា មានព្រះពុទ្ធរូបស្នងព្រះអង្គជាប្រធាន ។ មិនខុសគ្នាពីវីរបុរសវីរនារី ដែលធ្វើប្រយោជន៍ឲ្យសង្គម ពេលចែកឋានទៅ គេគូរឬឆ្លាក់រូបទុកជាអនុស្សាវរីយ៍ សំរាប់មនុ ស្សជំនាន់ក្រោយគោរពបូជា ។ ដូច្នេះពុទ្ធសាសនិកជនថ្វាយបង្គំព្រះពុទ្ធរូបនោះ តែងនឹកដល់គុណរបស់ព្រះអង្គមានព្រះនាមថា អរហំសម្មាសម្ពុទ្ធោជាដើម រមែងបានបុណ្យកុសល ពុំមែនថ្វាយបង្គំសម្ភារៈដែលយកមកធ្វើមានស៊ីម៉ង់ត៍ជាដើមឡើយ បានជាប្រធានបទខាងដើមនោះរំឭក ដើម្បីកុំឲ្យប្រើចិត្តខុស ។

ថ្វាយបង្គំព្រះសង្ឃ ប្រយ័ត្នប៉ះកូនអ្នកស្រុក ។ ចំពោះព្រះសង្ឃដែលបានមកបួស សុទ្ធតែចេញមកពីត្រកូលផ្សេងៗគ្នាមានឋានៈខ្ពស់ទាបជាងគ្នា លុះបានបួសហើយមានឋានៈតែមួយ ស្ថិតនៅក្រោមធម៌វិន័យរបស់ព្រះពុទ្ធ ត្រូវគោរពគ្នាទៅតាមការបួសមុនបួសក្រោយ និងទៅតាមគុណធម៌ ។ អ្នកបួសលោកចាត់ទុកជាឧត្តមភេទ ជាភេទខ្ពង់ខ្ពស់ប្រសើរ ដោយបានលះបង់កាមគុណគ្រប់យ៉ាង មករស់នៅក្នុងទីស្ងប់ស្ងាត់ដែលហៅថាវត្ត ខំព្យាយាមសិក្សារៀនសូត្រធម៌វិន័យ និងអប់រំចិត្ត ។ ព្រះសង្ឃដែលមានគុណធម៌បែបនេះហើយ បានជាពុទ្ធបរិស័ទគោរពបូជា គឺគោរពគុណធម៌របស់លោកមានសីលគុណជាដើម ទោះបីលោកចេញមកពីត្រកូលណាក៏ដោយ លុះបួសហើយទុកជាកូនចៅរបស់ព្រះពុទ្ធ ពុំមែននៅជាកូនចៅរបស់អ្នកស្រុកដូចមុនឡើយ ។ សូម្បីព្រះពុទ្ធជាម្ចាស់ក៏ព្រះអង្គចេញមកពីសាក្យត្រកូល លុះបានត្រាស់ជាព្រះពុទ្ធ ព្រះអង្គក្លាយជាវង្សត្រកូលរបស់ព្រះពុទ្ធទាំងឡាយវិញ ។ គេថ្វាយបង្គំព្រះពុទ្ធ ដោយនឹកដល់បញ្ញាញាណការត្រាស់ដឹងរបស់ព្រះអង្គ ពុំមែននឹកដល់សាក្យត្រកូលរបស់ព្រះអង្គឡើយ ។

ថ្វាយបង្គំព្រះធម៌ ប្រយ័ត្នប៉ះសាស្ត្រាស្លឹករឹត ។ កាលពីសម័យដើម ធម៌វិន័យរបស់ព្រះពុទ្ធសាសនាត្រូវគេចារលើសាស្ត្រាស្លឹករឹត ក្រោយមកទើបបោះពុម្ពជាសៀវភៅនៅលើក្រដាស ។ ពុទ្ធវចនៈ ទោះបីចារលើសាស្ត្រាស្លឹករឹតក្ដី លើក្រដាសក្ដី ជាពាក្យពិត គេលើកយកមកសិក្សានិងប្រតិបត្តិតាម ។ ពុទ្ធបរិស័ទខ្មែរឃើញសាស្ត្រាស្លឹករឹត ឃើញសៀវភៅធម៌ពុំហ៊ានដើរជាន់ឬដើរកន្លងឡើយ ដោយសារគោរពព្រះធម៌និងវិន័យ ដែលសរសេរលើសម្ភារៈទាំងនោះ ។ មានពាក្យខ្មែរថា ជនណាបានចារពាក្យព្រះពុទ្ធដាក់នៅក្នុងសាស្ត្រស្លឹករឹត ហើយចែកជាធម្មទានឲ្យគេយកទៅអាន ក្នុងអក្សរមួយអង្គៗបានបុណ្យមួយអនន្តព្រោះការចារនោះមានការលំបាកខុសពីបច្ចុប្បន្ននេះ មានម៉ាស៊ីនចម្លងដាក់លើក្រដាសបានឆាប់រហ័ស ។ ព្រះពុទ្ធបានសំដែងចំពោះព្រះអានន្ទថា ឥតពីតថាគតទៅ ធម៌និងព្រះវិន័យនេះហើយជាគ្រូរបស់អ្នករាល់គ្នា ។ ក្នុងន័យនេះហើយ បានជាពុទ្ធសាសនិកជនខ្មែរគោរពព្រះធម៌ដែលមានក្នុងសាស្ត្រាស្លឹករឹត និងនៅក្នុងសៀវភៅធម៌ ពុំមែនគោរពស្លឹករឹត ឬក្រដាសឡើយ គ្រាន់តែវត្ថុទាំងនោះគេយកមកធ្វើជាឧបករណ៍សំរាប់ចារ ឬសរសេរធម៌វិន័យប៉ុណ្ណោះ ។

☆ ☆

☆

ប្រ

☆ ☆

☆